NSW GOVERNMENT | Health

Khmer
[DOH-8105]

# សំណួរ និងចម្លើយ: ជាតិក្រខ្វក់នៃគ្រាប់ Bindeez ™ (គ្រាប់ប៊ីនឌីស – សំរាប់ក្មេងលេង)

## តើមានបញ្ហាអ្វីជាមួយគ្រាប់ Bindeez?

មានការបង្ហាញឲ្យឃើញថា ជាតិពុលគីមីត្រូវបានគេយកប្រើនៅក្នុងគ្រាប់ទាំងនេះ ជំនួសជាតិគីមីដែលមានសុវត្ថិភាព។ ពេលណាលេបចូលទៅក្នុងពោះ ជាតិគីមីនេះនឹងផ្លាស់ប្តូរទៅជាគ្រឿងញៀន GHB នៅក្នុងដងខ្លួន។

## តើ GHB ជាអ្វី?

GHB (gamma hydroxy butyrate) គឺជាថ្នាំរម្ងាប់ការឈឺចាប់ ហើយជាថ្នាំសន្លប់ ឬថ្នាំស្ពឹក។

## តើមានរោគសញ្ញាអ្វីខ្លះដែលបង្ហាញឲ្យដឹងថាកុមារត្រូវបានប៉ះពាល់ដោយ GHB?

រោគសញ្ញាមានការប្រែប្រួល ដោយយោងទៅតាមចំនួននៃគ្រាប់ដែលបានលេប។

កុមារដែលបានប៉ះពាល់មិនសូវខ្លាំង អាចមានការងងុយគេង ឬមិនសូវមានភាពរួញរាបន្តិចបន្តួច។ ប្រសិនបើបានលេបចំនួនច្រើនគ្រាប់ កុមារអាចកើតក្អួតចង្អោរ វិលមុខ និយាយឡុលៗមិនច្បាស់ ទៅជាងងុយគេងយ៉ាងខ្លាំង ឬមានការប្រកាច់។

រោគសញ្ញាទាំងអស់នឹងកន្លងបាត់ទៅក្នុងរយៈពេលពីរ ឬបីម៉ោង។

## តើខ្ញុំត្រូវធ្វើដូចម្តេច ប្រសិនបើកូនរបស់ខ្ញុំបង្ហាញឲ្យឃើញថាបានប៉ះពាល់ដោយ GHB?

ចំពោះកុមារដែលបានប៉ះពាល់មិនសូវខ្លាំង ត្រូវទៅជួបវេជ្ជបណ្ឌិត (GP) របស់លោកអ្នក ឬមន្ទីរពេទ្យក្នុងតំបន់។ ប្រសិនបើកើតមានរោគសញ្ញាធ្ងន់ធ្ងរ ត្រូវទូរស័ព្ទហៅឡានពេទ្យ។

មាតាបិតាមិនគួរធ្វើឲ្យកូនក្អួតឡើយ។

## ចុះប្រសិនបើកុមារបានលេងជាមួយគ្រាប់ Bindeez?

មាតាបិតាគួរយកគ្រាប់ទាំងនោះចេញពីកុមារ ហើយដាក់ឲ្យផុតពីដៃក្មេង។ កុមារណាដែលមិនបានលេបគ្រាប់ណាមួយទេ ហើយមិនបង្ហាញឲ្យឃើញថាមានរោគសញ្ញានៃការងងុយគេង ឬក្អួតចង្អោរ នោះគេមិនទំនងជាបានប៉ះពាល់ទេ។ លោកអ្នកអាចឃ្លាំមើលកុមារទាំងនេះនៅផ្ទះ – ប្រសិនបើពុំឃើញរោគសញ្ញាកើតមានក្នុងរយៈពេល១ម៉ោងទេ នេះមិនទំនងថាគេបានប៉ះពាល់ឡើយ។

ការគ្រាន់តែបានលេងប៉ះជាមួយគ្រាប់ ឬគ្រាប់ផ្គុំជារូបភាព មិនត្រូវចាត់ទុកថាបណ្តាលឲ្យកើតមានប្រតិកម្មដល់សុខភាពឡើយ។

## តើខ្ញុំត្រូវធ្វើដូចម្តេចជាមួយគ្រាប់ Bindeez?

លោកអ្នកត្រូវយកគ្រាប់ Bindeez ចេញ ហើយរក្សាវាទុកឲ្យផុតពីដៃក្មេង។ មាតាបិតាគួរបញ្ជូនផលិតផលនោះទៅឲ្យអ្នកចែកចាយ ឬអ្នកលក់វិញឲ្យបានឆាប់ដែលអាចធ្វើទៅបាន ដោយធ្វើតាមការណែនាំនៅតាមវិបសាយរបស់អ្នកចែកចាយ: http://www.mooseworld.com.au/content/bindeezrecall/faq.aspx ឬដោយទូរស័ព្ទទៅ Moose Enterprises លេខ **1800 303 895**។

ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀតអំពីប្រតិកម្មដល់សុខភាព សូមទាក់ទងជាមួយ **មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីថ្នាំពុល (Poisons Information Centre)** តាមទូរស័ព្ទលេខ **131 126** ឬអង្គភាពសុខភាពសាធារណៈក្នុងតំបន់របស់លោកអ្នក:

| | | | | | | | |
|---|---|---|---|---|---|---|---|
| Camperdown | 02 9515 9420 | Penrith | 02 4734 2022 | Broken Hill | 08 8080 1499 | Newcastle | 02 4924 6477 |
| Gosford | 02 4349 4845 | Randwick | 02 9382 8333 | Dubbo | 02 6841 5569 | Port Macquarie | 02 6588 2750 |
| Hornsby | 02 9477 9400 | Albury | 02 6080 8900 | Goulburn | 02 4824 1837 | Tamworth | 02 6767 8630 |
| Parramatta | 02 9840 3603 | Bathurst | 02 6339 5601 | Lismore | 02 6620 7500 | Wollongong | 02 4221 6700 |

**ចំពោះជំនួយខាងផ្នែកពេទ្យក្នុងគ្រាបន្ទាន់ សូមទូរស័ព្ទលេខ 000**